KHMER

# តើធ្វើដូចម្តេចទើបខ្ញុំដឹងថា ការបំបៅដោះ មានដំណើរការល្អ?

**(How can I tell that breastfeeding is going well?)**

ប្រសិនបើអ្នកឃើញមានសញ្ញាគូសនៅខាងស្តាំដៃ (ខាងក្រហម) សូមនិយាយជាមួយឆ្មប ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ ដើម្បីមានការធានាទំនុកចិត្ត ឬសុំដំបូន្មានអំពីការបំបៅរបស់ទារកអ្នក។

វាជាការប្រសើរសម្រាប់ទារករបស់អ្នក និងអ្នកដែលទទួលបានការគាំទ្រពីអ្នកជំនាញចាប់តាំងពីគ្រាដំបូង។

| ☺ ការបំបៅដោះមានដំណើរការល្អ ពេលណា៖ | | ☹ សូមនិយាយជាមួយឆ្មប ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសាររបស់អ្នក ប្រសិនបើ៖ | |
|---|---|---|---|
| ទារករបស់អ្នកបានបំបៅ 8 ដង ឬច្រើនជាងនេះ ក្នុងរយៈពេល 24 ម៉ោង | | ទារករបស់អ្នកចេះតែងងុយគេង ហើយបានបំបៅតិចជាង 6 ដង ក្នុងរយៈពេល 24 ម៉ោង | |
| ទារករបស់អ្នកបំបៅបានរវាង 5 ទៅ 40 នាទី នៅរាល់ការបំបៅម្តងៗ | | ទារករបស់អ្នកបំបៅ**បានតែ**រយៈពេល 5 នាទី ឬតិចជាងនេះ នៅរាល់ការបំបៅម្តងៗយ៉ាងជាប់លាប់<br>ទារករបស់អ្នកបំបៅ**បានតែ**រយៈពេលយូរជាង 40 នាទី នៅរាល់ការបំបៅម្តងៗយ៉ាងជាប់លាប់ | |
| | | ទារករបស់អ្នកចេះតែងងុយគេងនៅពេលបំបៅនឹងដោះ ហើយ/ឬមិនដែលបញ្ចប់ការបំបៅដោយខ្លួនឯង | |
| ទារករបស់អ្នកមានពណ៌សម្បុរស្បែកធម្មតា | | ទារករបស់អ្នកហាក់បីដូចជាមានជម្ងឺខាន់លឿង (ស្បែកប្រែទៅជាពណ៌លឿង)<br>ជាធម្មតា វាចាប់ផ្តើមនៅលើមុខទារក ហើយបន្ទាប់មករាលដាលដល់រាងកាយ ដៃ និងជើង។<br>**សូមអញ្ជើញទៅគ្លីនិកសុខភាពកុមារ និងគ្រួសាររបស់អ្នក ដែលទ្រទ្រង់ការបំបៅដោះ ឬវេជ្ជបណ្ឌិតពិនិត្យរោគទូទៅរបស់អ្នក ប្រសិនបើបញ្ហានេះកាន់តែកើនឡើង ហើយ/ឬកូនរបស់អ្នកចេះតែងងុយគេង** | |
| ជាទូទៅ ទារករបស់អ្នកស្ងប់ស្ងាត់ ហើយបន្ធូរខ្លួនប្រាណ ខណៈពេលកំពុងបំបៅ ហើយភាគច្រើនឆ្អែតស្កប់ស្កល់បន្ទាប់ពីការបំបៅ | | ទារករបស់អ្នកបំបៅ រួចហើយខ្ទាក់ចេញពីដោះជាញឹកញាប់ក្នុងអំឡុងពេលបំបៅ ឬប្រកែកមិនព្រមបៅដោះ | |
| ទារករបស់អ្នកមាននោម ហើយជុះដាក់កន្ទប (សូមមើលតារាងនៅទំព័រម្ខាងទៀត) | | ទារករបស់អ្នកមិននោម ហើយមិនជុះដាក់កន្ទប (សូមមើលការពន្យល់នៅទំព័រម្ខាងទៀត) | |
| ការបំបៅដោះមានភាពសុខស្រួល | | អ្នកកំពុងឈឺដោះ ឬក្បាលដោះរបស់អ្នក មិនបានធូរស្បើយ បន្ទាប់ពីទារកជញ្ជក់បានពីរបីដងដំបូង។<br>ក្បាលដោះរបស់អ្នករបូតចេញពីមាត់ទារក ហើយមើលទៅហាក់បីដូចត្រូវគាបខ្ទឹប ឬឡើងសំប៉ែតនៅពីម្ខាង | |
| ដោះរបស់អ្នកមានសភាពទន់ជ្រាយច្រើន បន្ទាប់ពីការបំបៅ | | ដោះរបស់អ្នកមិនមានសភាពទន់ ឬវាមានកកដុំៗនៅខាងក្នុង ឬពណ៌ក្រហមក្រោយពេលបំបៅ | |
| នៅពេលទារករបស់អ្នកមានអាយុ 3–4 ថ្ងៃ និងលើសពីនេះ អ្នកគួរតែអាចឮសូរទារករបស់អ្នកលេបបានញឹកញាប់ ក្នុងពេលបំបៅ | | អ្នកមិនអាចប្រាប់បានថាតើទារករបស់អ្នកកំពុងលេបទឹកដោះ នៅពេលទារករបស់អ្នកអាយុ 3–4 ថ្ងៃ ឬលើសពីនេះ | |
| | | អ្នកគិតថាទារករបស់អ្នកត្រូវការក្បាលដោះជ័រ | |
| | | អ្នកមានអារម្មណ៍ថា អ្នកត្រូវការផ្តល់ម្សៅទឹកដោះគោឱ្យទារករបស់អ្នក | |

យកលំនាំតាមដោយមានការអនុញ្ញាតពី គំនិតផ្តួចផ្តើមសុខភាពមិត្តភាពទារក UNICEF (UNICEF Baby Friendly Health Initiative) ដោយក្រុមអ្នកចាប់អារម្មណ៍ការបំបៅកូននឹងដោះ SLHD (SLHD Breastfeeding Interest Group) ជាមួយនឹងការពិគ្រោះយោបល់របស់អតិថិជន។ ត្រូវបានវាយតម្លៃដោយក្រុមគ្រួសារដែលទទួលសេវាកម្មសុខភាពកុមារ និងគ្រួសារ SLHD - ឆ្នាំ 2017

5/03/18 2:18 PM

NSW GOVERNMENT Health
South Western Sydney
Local Health District

តើធ្វើដូចម្តេចទើបខ្ញុំដឹងថាការបំបៅដោះមានដំណើរការល្អ?

# តើធ្វើដូចម្តេចទើបខ្ញុំដឹងថា ទារករបស់ខ្ញុំបានបំបៅគ្រប់គ្រាន់ ? ( How do I know my baby is getting enough ? )

**អ្វីៗក្នុងកន្ទបរបស់ទារកអ្នកនឹងផ្លាស់ប្តូរ ក្នុងអំឡុងសប្តាហ៍ដំបូង។ ការផ្លាស់ប្តូរទាំងនេះនឹងជួយអ្នកឱ្យបានដឹង ថាតើការបំបៅមានដំណើរការល្អឬអត់។ សូមនិយាយជាមួយឆ្មប ឬគិលានុបដ្ឋាក ផ្នែកសុខភាពកុមារ និងគ្រួសាររបស់អ្នក ប្រសិនបើអ្នកមានកង្វល់ណាមួយ។ សូមគូសសញ្ញាក្នុងជួរឈរ។**

| អាយុរបស់ទារក | កន្ទបសើម | | កន្ទបកខ្វក់ | | តើ 'លាមក' នេះ មើលទៅមានលក្ខណៈដូចម្តេចដែរ ? |
|---|---|---|---|---|---|
| អាយុ 1–2 ថ្ងៃ | 1–2 ឬច្រើនជាងនេះក្នុងមួយថ្ងៃ<br>អ៊ុយរ៉ាត (urates) អាចនៅមានរហូតដល់ថ្ងៃទី 4*<br>( សូមមើលការពន្យល់ខាងក្រោម ) | | 1 ឬច្រើនជាងនេះ 'ដូចជ័រស្អិត' ពណ៌បៃតងក្រម៉ៅ/ឬខ្មៅ ដែលគេហៅថា *លាមកព្រៃរបស់ទារកទើបកើត* | |  |
| អាយុ 3–4 ថ្ងៃ | 3 ឬច្រើនជាងនេះក្នុងមួយថ្ងៃ។ កន្ទបស្ទាបមើលទៅហាក់បីដូចជាធ្ងន់ជាងធម្មតា។ ទារកស្រីខ្លះ ចេញដំណើរមានរដូវមិនពិត ដែលជារឿងធម្មតាទេ** ( សូមមើលការពន្យល់ខាងក្រោម ) | | ការផ្លាស់ប្តូរពណ៌ និងមានភាពស្អិតស្អេរ - ពណ៌បៃតង/ត្នោត/លឿង មានសភាពកាន់តែទន់ ('ផ្លាស់ប្តូរលាមក') | |  |
| អាយុ 5–6 ថ្ងៃ | 5 ឬច្រើនជាងនេះ សើមធ្ងន់<br>ជាញឹកញាប់ ជាមួយនឹងកន្ទបដែលប្រើរួចបោះចោល វាពិបាកនឹងប្រាប់ថាកន្ទបសើមឬក៏អត់។ ដូច្នេះដើម្បីឱ្យបានដឹងថាតើមានទឹកនោមគ្រប់គ្រាន់ឬក៏អត់ ចូរយកកន្ទបមួយ ហើយចាក់ទឹកបន្ថែម 2-4 ស្លាបព្រាបាយ។ នេះនឹងផ្តល់ឱ្យអ្នកនូវគំនិតដើម្បីស្វែងរក/ស្ទាបមើល។ | | យ៉ាងហោចណាស់ 2 ពណ៌លឿង អាចទទឹកជោគ | |  |
| អាយុ 7–28 ថ្ងៃ | 6 ឬច្រើនជាងនេះ ហើយសើមធ្ងន់ | | យ៉ាងហោចណាស់ 2 យ៉ាងហោចណាស់មានទំហំប៉ុនកាក់ 50 សេន ពណ៌លឿង ហើយជាញឹកញាប់ទទឹកជោគ មើលទៅ 'គ្រាប់ៗ' | | |
| អ៊ុយរ៉ាត (urates)* | អ៊ុយរ៉ាត គឺជាសារធាតុពណ៌ទឹកក្រូច/ក្រហមក្រម៉ៅ ដែលទារកជាច្រើនដុះចេញមកក្នុងរយៈពេលពីរបីថ្ងៃដំបូង។ នៅអាយុនេះ ពួកគេមិនជាបញ្ហាទេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើវាកើតមានរយៈពេលលើសពីពីរបីថ្ងៃដំបូង អ្នកគួរតែប្រាប់ឆ្មប/គិលានុបដ្ឋាកសុខភាពកុមារ និងគ្រួសាររបស់អ្នក ដោយព្រោះថានេះអាចជាសញ្ញាមួយដែលបង្ហាញថា ទារករបស់អ្នកមិនបានបំបៅទឹកដោះគ្រប់គ្រាន់។ | | | |  |
| ដំណើរមានរដូវមិនពិត** | *ដំណើរមានរដូវមិនពិត* ក្នុងសប្តាហ៍ដំបូង គឺការហូរចេញទឹករំអិលដែលមានឈាមពណ៌ព្រឿងៗចេញពីទ្វារមាស ដោយសារតែការដកចេញនៃអ័រម៉ូនរបស់ម្តាយក្រោយពេលសម្រាលកូន។ វាជារឿងធម្មតាទេ។ | | | |  |

យកលំនាំតាមដោយមានការអនុញ្ញាតពី គំនិតផ្តួចផ្តើមសុខភាពមិត្តភាពទារក UNICEF (UNICEF Baby Friendly Health Initiative) ដោយក្រុមអ្នកចាប់អារម្មណ៍ការបំបៅកូននឹងដោះ SLHD (SLHD Breastfeeding Interest Group) ជាមួយនឹងការពិគ្រោះយោបល់របស់អតិថិជន។

Created: January 2018
Review by: January 2020
AVS 83586